## ព័ត៌មានសម្រាប់ជនរងគ្រោះ

ច្បាប់ស្តីពីសិទ្ធិជនរងគ្រោះរបស់រដ្ឋកាលីហ្វ័រញ៉ា – ដែលគេស្គាល់ថាជាច្បាប់ Marsy ផ្តល់ជូនលោកអ្នកនូវសិទ្ធិសំខាន់ៗទាំងនេះ៖

- **ទទួលបានប្រាក់សម្រាប់ការខាតបង់របស់អ្នក។** ដាក់ពាក្យសុំប្រាក់ដើម្បីទូទាត់ការខាតបង់ទ្រព្យសម្បត្តិការចំណាយខាងវេជ្ជសាស្ត្រ ប្រាក់ឈ្នួលដែលខាតបង់របស់អ្នក និងការខាតបង់ផ្សេងទៀត។
- **និយាយអំពីរបៀបដែលបទក្រិដ្ឋមានផលប៉ះពាល់ដល់លោកអ្នក។** ប្រា ប់តុលាការអំពីរបៀបដែលបទក្រិដ្ឋមានផលប៉ះពាល់ដល់ជីវិតរស់នៅលោកអ្នក មុនពេលចុងចោទ ត្រូវបានផ្តន្ទាទោស។
- **ទទួលព័ត៌មានអំពីសំណុំរឿងព្រហ្មទណ្ឌ។** ស្នើសុំព័ត៌មានជាក់លាក់ពីព្រះរាជអាជ្ញាដែលទាក់ទងនឹងសំណុំរឿងនេះ។
- **ទទួលដីកាពីតុលាការ។** តុលាការអាចចេញដីកាការពារ ដើម្បីរក្សាចុងចោទឱ្យនៅឆ្ងាយពីលោកអ្នកឬបញ្ជាឱ្យបង់ថ្លៃសេវាមេធាវី ប្រសិនបើលោកអ្នកបានជួលមេធាវីឱ្យជួយសំណុំរឿងរបស់អ្នក។ តុលាការក៏អាចបញ្ជាឱ្យចុងចោទបង់ប្រាក់ជូនលោកអ្នកចំនួន $25,000 ដុល្លារឬច្រើនជាងនេះ ដោយសារការរំលោភសិទ្ធិស៊ីវិលរបស់អ្នកផងដែរ។ (ពិភាក្សាជាមួយមេធាវីអំពីសិទ្ធិរបស់អ្នកក្រោមច្បាប់ Ralph Act និងច្បាប់ Bane Act)
- ច្បាប់រដ្ឋកាលីហ្វ័រញ៉ាហាមឃាត់អាជ្ញាធរអនុវត្តច្បាប់ មិនឱ្យសាកសួរបុគ្គលនានាដែលរួមមានអ្នកដែលកំពុងរាយការណ៍ ឬជាជនរងគ្រោះពីឧក្រិដ្ឋកម្មដែលអាចកើតមានអំពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ លើកលែងតែព័ត៌មានចាំបាច់ដើម្បីបញ្ជាក់ជនរងគ្រោះសម្រាប់ទិដ្ឋាការ U (ជនរងគ្រោះនៃទិដ្ឋាការឧក្រិដ្ឋកម្ម) ឬទិដ្ឋាការ T (ជនរងគ្រោះនៃទិដ្ឋាការជួញដូរមនុស្ស) ។

Rev 3-2021 <Cambodian>

## កន្លែងដែលត្រូវស្វែងរកជំនួយ

សូមទាក់ទងតាមលេខទូរសព្ទ 911 ឬទៅមន្ទីរពេទ្យក្នុងមូលដ្ឋាន ប្រសិនបើលោកអ្នកត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់។ ដើម្បីដាក់របាយការណ៍ សូមទាក់ទងទីភ្នាក់ងារអនុវត្តច្បាប់នៅមូលដ្ឋានរបស់អ្នក។

***អង្គភាពសេវាកម្មជនរងគ្រោះរបស់ការិយាល័យអគ្គព្រះរាជអាជ្ញារដ្ឋកាលីហ្វ័រញ៉ា*** – *ផ្តល់ជូនការគាំទ្រ* ដល់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មនិងក្រុមគ្រួសាររបស់ពួកគេ និងព័ត៌មានពេញនៅទូទាំងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ។ សម្រាប់ព័ត៌មានបន្ថែម សូមហៅទូរសព្ទទៅលេខ (877) 433-9069 ឬចូលមើលវិបសាយ oag.ca.gov/hatecrimes។

***ក្រសួងការងារនិងលំនៅដ្ឋានយុត្តិធម៌នៃរដ្ឋកាលីហ្វ័រញ៉ា (DFEH)*** – ទីភ្នាក់ងាររដ្ឋដែលទទួលបន្ទុក

ផ្នែកអនុវត្តច្បាប់សិទ្ធិស៊ីវិលរបស់រដ្ឋកាលីហ្វ័រញ៉ានិងការការពារប្រជាពលរដ្ឋពីការរើសអើងដោយខុសច្បាប់ចំពោះការងារ ផ្ទះសម្បែង និងការស្នាក់នៅជាសាធារណៈ និងពីអំពើហិង្សានៃការស្អប់ខ្ពើម និងការជួញដូរមនុស្ស។ ក្រសួង DFEH ទទួលយកពាក្យបណ្តឹងទាមទារពីជនរងគ្រោះនៃអំពើហឹង្សានៃការស្អប់ខ្ពើមឬការគំរាមកំហែងនៃអំពើហិង្សាដោយផ្អែកលើក្រុមសង្គមជាក់ស្តែងឬក្រុមដែលគេគិតដល់ របស់ជនរងគ្រោះ ដែលក្រុមនេះមានការការពារពីច្បាប់។ សម្រាប់ព័ត៌មានអំពីរបៀបដាក់ពាក្យបណ្តឹងទាមទារ សូមចូលទៅគេហទំព័រ dfeh.ca.gov។

***មជ្ឈមណ្ឌលជំនួយសាក្សីជនរងគ្រោះនៃការិយាល័យមេធាវីមណ្ឌលមូលដ្ឋាន*** – ធ្វើការផ្ទាល់ជាមួយក្រុមប្រឹក្សាសំណងជនរងគ្រោះរដ្ឋកាលីហ្វ័រញ៉ា (CalVCP) ដើម្បីជួយជនរងគ្រោះនៅ**គ្រប់**ខោនធីទាំងអស់។ សម្រាប់ព័ត៌មានអំពីការិយាល័យនិងធនធានតាមមូលដ្ឋាន សូមចូលមើលវិបសាយ victims.ca.gov/victims/localhelp.aspx។

***ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក សេវាកម្មទំនាក់ទំនងសហគមន៍*** – ធ្វើការជាមួយក្រុមសហគមន៍ ដើម្បីដោះស្រាយជម្លោះសហគមន៍ និងការពារនិងឆ្លើយតបចំពោះអំពើឧក្រិដ្ឋកម្មតាមការចោទប្រកាន់។ សម្រាប់ព័ត៌មាន សូមចូលមើលវិបសាយ justice.gov/crs។

*ការបោះពុម្ពផ្សាយនេះ បានគាំទ្រដោយការផ្តល់ថវិកាដែលទទួលបានពីមូលនិធិ 2018 ជំនួយឥតសំណង(Grant Subaward Number VT20199504) តាមរយៈការិយាល័យសេវាកម្មសង្គ្រោះបន្ទាន់របស់អភិបាលរដ្ឋកាលីហ្វ័រញ៉ា (California Governor's Office of Emergency Services (CalOES))។*

# ការស្អប់ខ្ពើមអំពើឧក្រិដ្ឋកម្ម




## អ្វីដែលលោកអ្នកត្រូវដឹង ដើម្បីការពារខ្លួនអ្នកនិងអ្នកដទៃ

CALIFORNIA
DEPARTMENT OF JUSTICE
VICTIMS' SERVICES UNIT

**ក្រសួងយុត្តិធម៌រដ្ឋកាលីហ្វ័រញ៉ា (California Department of Justice) មានវិធីសាស្ត្រនិងធនធានដែលអាច**រកបាន ដើម្បីផ្តល់ជំនួយនិងគាំទ្រដល់អាជ្ញាធរអនុវត្តច្បាប់នៅមូលដ្ឋាន រដ្ឋ និងសហព័ន្ធក្នុងការសើបអង្កេតអំពីឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើមដែលអាចកើតមាន រួមមានការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន ការកាត់ទោស និងការផ្តន្ទាទោសជនល្មើសនៃឧក្រិដ្ឋកម្មទាំងនោះ។

**អគ្គព្រះរាជអាជ្ញារដ្ឋកាលីហ្វ័រញ៉ាលោក Rob Bonta ផ្តល់ជូនព័ត៌មានដូចខាងក្រោមអំពីរបៀបកំណត់**អត្តសញ្ញាណនិងរាយការណ៍អំពីឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើម និងសេវាកម្មនានាដែលជនរងគ្រោះក្នុងឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើមអាចរកបាន។

## *ឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើម ឬឧប្បត្តិហេតុនៃការស្អប់ខ្ពើម?*

វាមានសារៈសំខាន់ណាស់ដែលត្រូវដឹងពីភាពខុសគ្នារវាងឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើមនិងឧប្បត្តិហេតុនៃការស្អប់ខ្ពើម។

ឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើម គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ក្រុម ឬទ្រព្យសម្បត្តិ ហើយកត្តាដែលជំរុញឱ្យមានឧក្រិដ្ឋកម្មនេះ គឺក្រុមសង្គមដែលគេគិតដល់ ឬក្រុមជាក់ស្តែងរបស់ជនរងគ្រោះ ដែលជាក្រុមដែលមានការការពារពីច្បាប់។ ឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើមអាចត្រូវបានកាត់ទោសជាបទមជ្ឈិមឬបទឧក្រិដ្ឋអាស្រ័យលើអំពើដែលបានប្រព្រឹត្ត។

នៅរដ្ឋកាលីហ្វ័រញ៉ា លោកអ្នកអាចក្លាយជាជនរងគ្រោះម្នាក់នៃអំពើឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើម ប្រសិនបើលោកអ្នកត្រូវបានគេកំណត់ជាគោលដៅដោយសារតែភាពជាក់ស្តែង ឬអ្វីដែលគេគិតដល់អំពីអ្នកដូចជា៖

- ជាតិសាសន៍ ឬជនជាតិភាគតិច
- សញ្ជាតិ
- សាសនា
- ភេទ
- ការបង្ហាញផ្លូវភេទ
- ពិការភាពរាងកាយ ឬផ្លូវចិត្ត ឬ
- ការសេពគប់ជាមួយមនុស្សម្នាក់ ឬក្រុមដែលមានលក្ខណៈ “ជាក់ស្តែង” ឬ “ដែលគេគិតដល់” មួយឬច្រើនទាំងនេះ។

សូមកត់សម្គាល់ថាលក្ខណៈដែលបានរៀបរាប់ខាងលើ គឺជាឧទាហរណ៍ខ្លះៗ ហើយមូលដ្ឋានផ្សេងទៀតសម្រាប់លក្ខណៈក្រុមសង្គមជាក់ស្តែងឬដែលគេគិតដល់ ដែលមានការការពារ ក៏មានផងដែរ។

**ប្រសិនបើលោកអ្នកឃើញឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើម លោកអ្នកត្រូវរាយការណ៍ពីបទឧក្រិដ្ឋនេះទៅទីភ្នាក់ងារ អនុវត្តច្បាប់នៅមូលដ្ឋានបស់អ្នក។**

ឧប្បត្តិហេតុនៃការស្អប់ខ្ពើម គឺជាសកម្មភាពឬអាកប្បកិរិយាដែលបានជម្រុញដោយការស្អប់ខ្ពើម ប៉ុន្តែបានការពារដោយច្បាប់ ដោយសិទ្ធិវិសោធនកម្មលើកទីមួយចំពោះសេរីភាពនៃការបញ្ចេញមតិ។ ប្រសិនបើឧប្បត្តិហេតុនៃការស្អប់ខ្ពើម ចាប់ផ្តើមគំរាមកំហែងដល់មនុស្សឬទ្រព្យសម្បត្តិ វាអាចក្លាយជាបទឧក្រិដ្ឋនៃការស្អប់ខ្ពើម។

***ឧទាហរណ៍នៃឧប្បត្តិហេតុនៃការស្អប់ខ្ពើម រួមមាន៖***

- ការហៅឈ្មោះមិនល្អ។
- ការប្រមាថ។
- ការបង្ហាញសម្ភារៈដែលស្អប់ខ្ពើមនៅលើបរិវេណផ្ទាល់របស់អ្នក។
- ការបិទផ្សាយសម្ភារៈដែលស្អប់ខ្ពើម ដែលមិនបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិ។
- ការចែកចាយសម្ភារៈដែលមានសារស្អប់ខ្ពើមនៅកន្លែងសាធារណៈ។

## *របៀបរកឃើញអំពើឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើម*

**សញ្ញាដែលបង្ហាញថាឧក្រិដ្ឋកម្មមួយត្រូវបានជម្រុញឱ្យមានដោយការស្អប់ អាចមាន៖**

- ជនល្មើសបានជ្រើសរើសជនរងគ្រោះឬទ្រព្យសម្បត្តិពីព្រោះពួកគេស្ថិតនៅក្នុងក្រុមដែលមានការការពារ ដូចជាក្រុមសាសនា ឬភេទជាក់លាក់។
- ជនល្មើសបានធ្វើអត្ថាធិប្បាយជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដែលបង្ហាញពីការប្រកាន់
- ពូជសាសន៍។
- បទឧក្រិដ្ឋនេះ បានកើតឡើងនៅកាលបរិច្ឆេទដែលមានសារៈសំខាន់សម្រាប់ក្រុមដែលមានការការពាររបស់ជនរងគ្រោះ ឬជនល្មើស។
- មានសកម្មភាពនៃការស្អប់ខ្ពើមដែលរៀបចំឡើងនៅតាមតំបន់។

**ប្រសិនបើអ្នកជាជនរងគ្រោះនៃបទឧក្រិដ្ឋនៃការស្អប់ខ្ពើម លោកអ្នកត្រូវតែ៖**

- ទាក់ទងទីភ្នាក់ងារអនុវត្តច្បាប់នៅមូលដ្ឋានរបស់អ្នកភ្លាមៗ។
- ទទួលបានការយកចិត្តទុកដាក់ខាងវេជ្ជសាស្ត្រ (ប្រសិនបើលោកអ្នកត្រូវការ)។
- សរសេរពាក្យជាក់លាក់ដែលបាននិយាយ។
- ធ្វើកំណត់ហេតុអំពីអង្គហេតុផ្សេងទៀត។
- រក្សាទុកភ័ស្តុតាងទាំងអស់ (ឧទាហរណ៍ គំនូរតាមទីសាធារណៈ សំបកពងមាន់ ការសរសេរលើ
- យានយន្តរបស់ជនរងគ្រោះ)។ ប្រសិនបើមានសុវត្ថិភាព សូមរង់ចាំរហូតដល់ក្រុមការងារអនុវត្តច្បាប់មកដល់ ហើយថតរូប។
- សុំឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ និងអ៊ីមែលរបស់ជនរងគ្រោះ និងសាក្សីដទៃទៀត។
- ព្យាយាមទទួលបានការពិពណ៌នាពីសាក្សីដែលបានឃើញផ្ទាល់ភ្នែកពីឧក្រិដ្ឋជនឬយានយន្ត។
- ទាក់ទងអង្គការក្នុងសហគមន៍តាមមូលដ្ឋានរបស់អ្នកដែលឆ្លើយតបនឹងអំពើឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើម។

**អ្វីដែលលោកអ្នកនិងសហគមន៍របស់អ្នកអាចធ្វើបាន**

- និយាយប្រឆាំងដោយក្លាហានចំពោះការស្អប់ខ្ពើមនិងការមិនអត់ឱន។
- មានការប្រមូលផ្តុំសហគមន៍ ដើម្បីគាំទ្រជនរងគ្រោះ។
- ផ្តល់ការគាំទ្រនិងជំនួយដល់ជនរងគ្រោះ។
- ស្នើឱ្យមន្ត្រីសាធារណៈ និយាយប្រឆាំងដោយក្លាហានចំពោះអំពើឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើម។
- បង្កើតគណៈកម្មការទំនាក់ទំនងប្រជាពលរដ្ឋ ឬបណ្តាញឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើម ដែលរួមមានមន្ត្រី
- អនុវត្តច្បាប់ រដ្ឋាភិបាលមូលដ្ឋាន សាលារៀន អង្គការសាសនា និងអង្គការសហគមន៍។ ស្នើសុំឱ្យពួកគេឆ្លើយតបចំពោះអំពីឧក្រិដ្ឋកម្មនៃការស្អប់ខ្ពើមភ្លាមៗនៅពេលដែលកើតឡើងនិងដើម្បីលើកកម្ពស់ការការពារនិងការយល់ដឹង។

**OAG.CA.GOV/HATECRIMES**